# ការពិត ការចងចាំ និងយុត្តិធម៌

## ប្រវត្តិសាស្ត្រតាមរយៈការស្ទង់មតិក្នុងសហគមន៍ចាម និងការពិភាក្សាអំពីសារៈសំខាន់នៃការរៀបរាប់ពីបទពិសោធន៍ក្រោមរបបខ្មែរក្រហម


សុ ហ្វារីណា ប្រធានគម្រោង


ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០

# សំណួរពិភាក្សា

- ហេតុអ្វីបានជាត្រូវរំឭកពីរបបខ្មែរក្រហម?
- តើការរំឭកឡើងវិញពីបទពិសោធន៍ក្រោមរបបខ្មែរ ជួយឱ្យធូរស្បើយ ឬ កាន់តែធ្វើឱ្យឈឺចាប់?

# សំណួរពិភាក្សា

- តើការរក្សានិងអប់រំពីវប្បធម៌ ប្រវត្តិសាស្ត្រ សាសនា ទំនៀមទម្លាប់ប្រពៃណី មានសារៈសំខាន់យ៉ាងដូចម្តេច?



រូបថតវិហារសាសនាអ៊ីស្លាម អូរគ្រាវ ខេត្តព្រះសីហនុ, ឆ្នាំ២០១០

# អ្វីទៅជាប្រវត្តិសាស្ត្រតាមរយៈការសួរនាំ?

- គឺជាការសម្ភាសដោយប្រើម៉ាស៊ីនថតសំឡេងឬម៉ាស៊ីនការមេរ៉ា
- គឺជាការសន្ទនាអំពីអតីតកាល
- គឺជាការរៀបរាប់ពីសាច់រឿងពីអតីតកាលដោយផ្ទាល់មាត់
- គឺជាវិធីសាស្ត្របុរាណប៉ុន្តែមានអត្ថន័យក្នុងការប្រមូលចងក្រង សាច់រឿង ដែលមិនទាន់បានកាត់ត្រាពីប្រជាជននៅតាមភូមិ

# ប្រវត្តិគម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំ

- មានការឯកភាពពីសហគមន៍ចាម
- ការប្រជុំជាមួយអ្នកដឹកនាំសហគមន៍ចាម  នៅឆ្នាំ២០០៤
- កម្រងសំណួរអំពីបទពិសោធន៍ក្រោមរបបខ្មែរក្រហម
- ការសម្ភាសន៍នៅតាមសហគមន៍

# គោលបំណង និង សារៈសំខាន់

- រក្សាការចងចាំតាមរយៈការសន្ទនានិងការសួរនាំ
- ចូលរួមចំណែកក្នុងការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម
- ចូលរួមទប់ស្កាត់អំពើប្រល័យពូជសាសន៍និងការកាប់សម្លាប់

# គោលបំណង និង សារៈសំខាន់

- ផ្តល់ឱកាសនិងលើកទឹកចិត្តដល់អ្នកដែលមិនសូវមានឱកាសនិយាយ អាចរៀបរាប់ពីសាច់រឿងរបស់ខ្លួន ដែលនាំឱ្យមានការយល់ដឹងពីការពិតអំពីរបបខ្មែរក្រហមកាន់តែទូលំទូលាយ
- អប់រំក្មេងជំនាន់ក្រោយអំពីរបបខ្មែរក្រហម និងឱ្យចេះអត់ឱនអធ្យាស្រ័យគ្នា



សិស្សរៀនពីសាសនាអ៊ីស្លាមក្នុងភូមិស្វាយឃ្លាំង ខេត្តកំពង់ចាម, ឆ្នាំ២០១០

# គម្រោងនេះសង្កត់ធ្ងន់នៅលើផ្នែកធំៗ២

១. ប្រវត្តិសាស្ត្រតាមរយៈការសួរនាំ

◆យល់ដឹងពីរបបខ្មែរក្រហមកាន់តែទូលាយតាមរយៈបទសម្ភាសន៍ និងសាច់រឿងរបស់សហគមន៍ចាម

២. បន្តលក្ខណៈឱ្យប្រជាជនចូលរួមដំណើរការយុត្តិធម៌បានទូលំទូលាយ



ស្ត្រីអ៊ីស្លាមមកទស្សនកិច្ចមន្ទីរស-២១ (គុកទួលស្លែង) ឆ្នាំ២០០៨

- បទសម្ភាសន៍ : ៥០០
- សាច់រឿងអំពីបទពិសោធន៍ក្រោមរបបខ្មែរក្រហម : ១០០
- របស់របរបុរាណដែលរក្សាទុកពីសម័យខ្មែរក្រហម ដូចជា

ដាវ, ចាន, គីតាប (គម្ពីរសាសនាអ៊ីស្លាម), ថាសដាក់ បាយ...។

# ទស្សនៈមួយចំនួនរបស់ស្ត្រីចាមអំពីការរំឭកពីអតីតកាល

«...ត្រូវតែនិយាយរឿងរ៉ាវ [របបខ្មែរក្រហម] ប្រាប់ដល់ក្មេងជំនាន់ក្រោយដើម្បីឱ្យទាដឹងពីការឈឺចាប់ និងរៀនសូត្រពីរបបនោះ»។

«...ការរំឭកឡើងវិញ អាចធ្វើឱ្យយើងចងចាំ និងចៀសវាង [កុំឱ្យធ្វើតាមរបបខ្មែរក្រហម]»។

«...ការរៀបរាប់រឿងពីអតីតកាលធ្វើឱ្យមានការឈឺចាប់ ប៉ុន្តែក៏អាចជួយឱ្យធូរស្បើយមួយកម្រិត...»

# ការចងចាំរបស់ជនជាតិចាមពីរបបខ្មែរក្រហម និងការចូលរួមក្នុងគម្រោង

- ការបាត់បង់និងការឈឺចាប់មានទំហំធំធេងស្រដៀងគ្នា នឹងប្រជាជនទូទៅក្នុងប្រទេស
- មានភាពខ្លាំងក្នុងការនិយាយរឿងរ៉ាវរបស់ខ្លួន
- ចងចាំយ៉ាងខ្លាំងនូវរឿងផ្ទាល់ខ្លួននិងក្រុមគ្រួសារ ដែលអាចជួយកសាងសង្គមគ្រួសារថ្មីឱ្យកាន់តែរឹងមាំ

## ការចងចាំរបស់ជនជាតិចាមពីរបបខ្មែរក្រហម និងការចូលរួមក្នុងគម្រោង

- រកឃើញថា  ការសម្លាប់នៅលើជនជាតិចាមមាននៅគ្រប់ទីកន្លែង ប៉ុន្តែការសម្លាប់ដោយហេតុផលសាសនានិងជនជាតិ ខ្លាំងបំផុតនៅភូមិភាគបូព៌ា  (ខេត្តកំពង់ចាម) និងនៅឆ្នាំ១៩៧៧។
- ខិតខំប្រឹងប្រែងកសាងសហគមន៍ឡើងវិញក្រោយពីរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩



ការសម្ពោធពាក្យស្លោកអប់រំពីអំពើប្រល័យពូជសាសន៍ នៅវិទ្យាល័យឫស្សីកែវ, ខែតុលា ឆ្នាំ២០១០




យុវជនអ៊ីស្លាមនៅមុខបូជនីយដ្ឋានជើងឯក ឆ្នាំ២០០៨

សូមអរគុណ!